ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាខេត្តតាកែវ**
លេខ ...៣០៦....ស.ដ.ណ

តាកែវ ,ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១៣

សាលាខេត្តតាកែវ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក/លោកស្រី ជាម្ចាស់អចលនទ្រព្យជាប់ពន្ធទាំងអស់ ដែលមានទីតាំងស្ថិតនៅក្នុង ក្រុងដូនកែវ ខេត្តតាកែវ ជ្រាបថា: ការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១៣ មានម្ចាស់អចលនទ្រព្យភាគតិច បានអញ្ជើញមកប្រកាសបង់ពន្ធ និងមានម្ចាស់អចលនទ្រព្យមួយចំនួន នៅមិនទាន់មកបំពេញកាតព្វកិច្ច បង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១៣ នៅឡើយ ។ ក្នុងស្មារតីជំរុញឲ្យការបង់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ ២០១៣នេះ បានទាន់ពេលវេលា សាលាខេត្តតាកែវ សូមអញ្ជើញម្ចាស់អចលនទ្រព្យទាំងអស់ មេត្តារួសរាន់មកប្រកាសបង់ពន្ធនេះឲ្យបានមុនថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៣ ជៀសវាងនូវការប្រជ្រៀត គ្នានៅពេលជិតផុតកំណត់ ដែលនាំឲ្យខកខានពុំបានបង់ពន្ធនេះ និងទទួលរងនូវទោសទណ្ឌតាមច្បាប់ ស្តីពីសារពើពន្ធ។

ចំពោះម្ចាស់អចលនទ្រព្យដែលបានបង់ពន្ធក្នុងឆ្នាំ ២០១២ រួចហើយ ពេលអញ្ជើញមកបង់ពន្ធ សម្រាប់ឆ្នាំ ២០១៣ ត្រូវភ្ជាប់មកជាមួយនូវបង្កាន់ដៃបង់ពន្ធឆ្នាំចាស់ ។ ដោយឡែកម្ចាស់អចលនទ្រព្យ ដែល សាងសង់ថ្មី បំបែកដើម្បីលក់ ឬផ្ទេរ ឬផ្តល់ជាអំណោយ ឬតម្លៃមូលដ្ឋាន គិតពន្ធលើអចលនទ្រព្យ ត្រូវបានកែប្រែ ម្ចាស់អចលនទ្រព្យទាំងនោះត្រូវមកប្រកាសបង់ពន្ធជាថ្មី នៅសាខាពន្ធដារខេត្ត ។

សាលាខេត្តតាកែវ សង្ឃឹមនិងជឿជាក់ថា ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក/លោកស្រី ជាម្ចាស់អចលនទ្រព្យជាប់ពន្ធទាំងអស់ ពិតជាបានយល់ និងយកចិត្តទុកដាក់ អញ្ជើញមកបំពេញ កាតព្វកិច្ចបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១៣ ដើម្បីរួមចំណែកកសាង និងអភិវឌ្ឍន៍មូលដ្ឋាន ឲ្យបានល្អប្រសើរជាពុំខានឡើយ ។

**អភិបាលខេត្ត**

ស្រី បេន

<u>ចម្លងជូន:</u>
-ក្រសួងមហាផ្ទៃ
-គណៈកម្មការវាយតម្លៃអចលនទ្រព្យ
« ដើម្បីជូនជ្រាប »
-អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យខេត្ត
-សាលាក្រុងដូនកែវ
-ក្រុមការងារអចលនទ្រព្យ សង្កាត់ទាំងបី ក្នុងក្រុងដូនកែវ
« ដើម្បីផ្សព្វផ្សាយ និងសហការអនុវត្ត »
-ស្ថានីយ៍វិទ្យុគោកថ្លុកខេត្ត FM 92,50 MHz
« ដើម្បីផ្សព្វផ្សាយ »
-ឯកសារ-កាលប្បវត្តិ